ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១៤៣៤.....ឧស..បណ.សជ៧

# សេចក្តីជូនដំណឹង
## ស្តីពីការរៀបចំដំណើរការប្រឡងប្រជែងផ្ទៃក្នុង
## ដើម្បីប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល សម្រាប់ឆ្នាំ ២០១៤

- យោងប្រកាសលេខ ៥២៤ MIH/2014 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីការបើកឱ្យដំណើរការប្រឡងប្រជែងផ្ទៃក្នុងដើម្បីប្តូរប្រភេទក្របខ័ណ្ឌជូនមន្ត្រីរាជការស៊ីវិលសម្រាប់ឆ្នាំ ២០១៤
- យោងប្រកាសលេខ ៥២៥ MIH/2014 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីការបង្កើតគណៈកម្មការប្រឡងប្រជែងផ្ទៃក្នុងដើម្បីប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល

ក្រសួងឧស្សាហកម្ម និងសិប្បកម្មសូមជម្រាបជូនដំណឹងដល់គ្រប់អង្គភាព និងមន្ត្រីរាជការក្រោមឱវាទក្រសួងឱ្យបានជ្រាបថា ៖ ក្រសួងរៀបចំដំណើរការប្រឡងប្រជែងជ្រើសរើសផ្ទៃក្នុងដើម្បីប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលសម្រាប់ឆ្នាំ២០១៤ នេះ ដោយមិនកំណត់លក្ខខណ្ឌអាយុ ចំនួន ២៥០កន្លែង ក្នុងនោះ:

- ការប្រឡងប្តូរចូលក្របខ័ណ្ឌប្រភេទ "**ក**" ចំនួន ១៥០ កន្លែង
- ការប្រឡងប្តូរចូលក្របខ័ណ្ឌប្រភេទ "**ខ**" ចំនួន ១០០កន្លែង

### ១- លក្ខខណ្ឌចុះឈ្មោះប្រឡង ៖

- មន្ត្រីរាជការទាំងពីរភេទដែលមានអតីតភាពការងារលើសពី០៥ឆ្នាំ គិតចាប់ពីថ្ងៃតាំងស៊ប់ក្នុងក្របខ័ណ្ឌ
- ការប្រឡងប្រជែងចូលក្នុងក្របខ័ណ្ឌប្រភេទ "**ក**" ៖
  ជាមន្ត្រីរាជការស៊ីវិលដែលស្ថិតនៅយ៉ាងតិចបំផុតក្នុងថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី ៣ នៃ ក្របខ័ណ្ឌប្រភេទ "**ខ**" (ខ.៣.១១) ឬមន្ត្រីរាជការស៊ីវិលដែលមានសញ្ញាបត្រសមមូលនឹងបរិញ្ញាបត្រ ដោយពុំគិតពីលក្ខខណ្ឌឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ។
- ការប្រឡងប្រជែងចូលក្នុងក្របខ័ណ្ឌប្រភេទ "**ខ**" ៖
  ជាមន្ត្រីរាជការស៊ីវិលដែលស្ថិតនៅយ៉ាងតិចបំផុតក្នុងថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌប្រភេទ "**គ**" (គ.៣.១១) ឬមន្ត្រីរាជការស៊ីវិលដែលមានសញ្ញាបត្រសមមូលនឹងបរិញ្ញាបត្ររង ឬមានសញ្ញាបត្រសមមូលនិងមធ្យមសិក្សាប័ត្រភាគីទី២+២ឆ្នាំសិក្សា ក្នុងគ្រឹះស្ថានឧត្តមសិក្សា ដោយពុំគិតពីលក្ខខណ្ឌឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ។

### ២- សំណុំលិខិតសុំចុះឈ្មោះប្រឡង ៖

| | |
|---|---|
| ១. ពាក្យសុំចុះឈ្មោះប្រឡងមានបិទតែម | ០១ច្បាប់ |
| ២.សេចក្តីចម្លងសញ្ញាបត្រ ដោយមានបញ្ជាក់ទទួលស្គាល់ជាផ្លូវការ (ជម្រើសតាមសញ្ញាបត្រ) | ០១ច្បាប់ |
| ៣.ប្រកាសដំឡើងថ្នាក់ចុងក្រោយ (ជម្រើសតាមអតីតភាពការងារ) | ០១ច្បាប់ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

៤. ជីវប្រវត្តិសង្ខេបមានបិទរូបថត (៤x៦) ០១ច្បាប់
៥. សលាកប័ត្រឯកត្តជន ០១ច្បាប់
៦. រូបថត (៤x៦) ០១សន្លឹក
៧. បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង ០១ច្បាប់

**៣- កាលបរិច្ឆេទទទួលពាក្យ និងទីកន្លែងទទួលពាក្យសុំប្រឡង ៖**

- កាលបរិច្ឆេទទទួលពាក្យ ៖
  ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រៀងរាល់ពេលម៉ោងធ្វើការងារ ពេលព្រឹកចាប់ពីម៉ោង ៧: ៣០ រហូតដល់ម៉ោង ១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:៣០ ដល់ម៉ោង ១៧:០០ នាទី។
- កាលបរិច្ឆេទឈប់ទទួលពាក្យ ៖ ថ្ងៃ សុក្រ ទី ០៣ ខែ តុលា ឆ្នាំ២០១៤ ត្រឹមវេលាម៉ោង ១៧: ០០នាទី ជាកាលបរិច្ឆេទចុងក្រោយ។
- ទីកន្លែងទំនាក់ទំនង និងទទួលពាក្យ ៖ នៅលេខាធិការដ្ឋាននៃគណៈកម្មការប្រឡងប្រជែងផ្ទៃក្នុងរបស់ក្រសួង (នាយកដ្ឋានបុគ្គលិក)។

**៤-វិញ្ញាសាប្រឡង ៖**

- វិញ្ញាសាសរសេរ(ចំណេះដឹងទូទៅពាក់ព័ន្ធនឹងរដ្ឋបាលសាធារណៈ ឬមុខងារភារកិច្ចក្រសួងឧស្សាហកម្ម និងសិប្បកម្ម)......រយៈពេល ០២ ម៉ោង
- វិញ្ញាសាសួរផ្ទាល់មាត់ រយៈពេលមិនលើសពី ១០ នាទី ក្នុងបេក្ខជនម្នាក់

**៥- កាលបរិច្ឆេទ និងមណ្ឌលប្រឡង ៖**

ក្រសួងនឹងជូនដំណឹងពេលក្រោយឲ្យបានមុនរយៈពេល ០៥ ថ្ងៃ នៃកាលបរិច្ឆេទប្រឡង។ ដើម្បីជៀសវាងការខកខានដោយប្រការណាមួយ សូមបេក្ខជនតាមដានព័ត៌មាននៅលេខាធិការដ្ឋានគណៈកម្មការប្រឡង និងពិនិត្យ នៅក្នុងវេបសាយរបស់ក្រសួង ដែលមានអាសយដ្ឋាន www.mih.gov.kh ។

ព័ត៌មានលម្អិត សូមមកទំនាក់ទំនងនៅនាយកដ្ឋានបុគ្គលិក រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមគ្រប់អង្គភាពនៅរដ្ឋបាលថ្នាក់កណ្តាល និងនៅថ្នាក់រាជធានី-ខេត្ត ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ត្រីរាជការក្រោមឱវាទ និងសូមមន្ត្រីរាជការទាំងអស់ជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១៤
**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**គឹម ទូច**

កន្លែងទទួល៖
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  *"ដើម្បីជូនជ្រាប"*
- គ្រប់អង្គភាពចំណុះក្រសួងឧស្សាហកម្ម និងសិប្បកម្ម
  *"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ